ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ចម្លើយតប

## សំណួររបស់ឧត្តមស្នងការសិទ្ធិមនុស្ស

## នៃអង្គការសហប្រជាជាតិ

# ទាក់ទងការលក់សរីរៈកុមារ

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៧

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ..... ១

**ផ្នែកទី១ : ការលក់សរីរៈ** ..... ១

**- បរិបទច្បាប់ និងបទដ្ឋានអនុវត្ត** ..... ១

- សំណួរទី១ និង ចម្លើយ..... ១-២
- សំណួរទី២ និង ចម្លើយ..... ២-៣
- សំណួរទី៣ និង ចម្លើយ..... ៣-៤
- សំណួរទី៤ និង ចម្លើយ..... ៤-៧

**- បរិបទអង្គហេតុ** ..... ៧

- សំណួរទី៥ និង ចម្លើយ..... ៧
- សំណួរទី៦ និង ចម្លើយ..... ៧
- សំណួរទី៧ និង ចម្លើយ..... ៧
- សំណួរទី៨ និង ចម្លើយ..... ៨
- សំណួរទី៩ និង ចម្លើយ..... ៨

**ផ្នែកទី២ : កម្មវិធីដោះស្រាយជាបន្ទាន់ ក្នុងករណីមានការចាប់ខ្លួន ឬ ការបាត់ខ្លួនកុមារ** ..... ៨

**- បរិបទច្បាប់ និងបទដ្ឋានអនុវត្ត** ..... ៨

- សំណួរទី១0 និង ចម្លើយ..... ៨
- សំណួរទី១១ និង ចម្លើយ..... ៩

**- បរិបទអង្គហេតុ** ..... ៩

- សំណួរទី១២ និង ចម្លើយ..... ៩
- សំណួរទី១៣ និង ចម្លើយ..... ៩

**សេចក្តីសន្និដ្ឋាន** ..... ៩


~~~~~~~~~~
~~~~~~~~~~

## សេចក្តីផ្តើម

ការលក់ដូរមនុស្ស ដើម្បីបម្រើគោលបំណងផ្សេងៗ និងការចាប់មនុស្ស ដើម្បីយកទៅធ្វើពិធីបូជាយញ្ញ គឺជាសកម្មភាពដែលកើតមាននៅលើពិភពលោក កាលពីសម័យទាសភាព សកម្មភាពទាំងនេះ ត្រូវបានលុបបំបាត់ជាលំដាប់ទៅតាមការវិវត្តរបស់សង្គម ។ ការអភិវឌ្ឍនូវទស្សនៈ និងច្បាប់នានា ពិសេសអនុសញ្ញាអន្តរជាតិនៃ អ.ស.ប ស្តីពីសិទ្ធិមនុស្សនិងសិទ្ធិកុមារ ។ ទោះយ៉ាងណាក៏ដោយ ការលក់ដូរមនុស្ស ការបាត់ខ្លួន ការចាប់ខ្លួន ពិសេសការលក់កុមារក្នុងគោលបំណងធ្វើអាជីវកម្មផ្លូវភេទ ឬកេងប្រវ័ញ្ចកម្លាំងពលកម្ម នៅតែអាចកើតមានដោយលួចលាក់ ហើយក៏មានផងដែរនូវការលក់សរីរៈដោយធ្វើការវះកាត់តាមវិធីវេជ្ជសាស្ត្រ ដើម្បីផ្លាស់ប្តូរសរីរៈជនដែលមានជំងឺ ។ ដោយឡែកនៅកម្ពុជា បញ្ហានេះគ្មានទេ ។

នៅកម្ពុជា ក្នុងចន្លោះឆ្នាំ១៩៧៥-៧៩ ក្រោមការគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ សិទ្ធិរបស់កុមារត្រូវបានលុបបំបាត់ កុមារត្រូវបានគេបង្ខំឱ្យធ្វើពលកម្មយ៉ាងធ្ងន់ធ្ងរ ត្រូវទទួលរងទារុណកម្មយ៉ាងខ្លោចផ្សា និងត្រូវបានកាប់សម្លាប់ជាបន្តបន្ទាប់រួមជាមួយក្រុមគ្រួសារ ។ ក្រោយថ្ងៃដួលរលំនៃរបបនេះ កុមារត្រូវបានជួយសង្គ្រោះជីវិត ត្រូវបានគាំទ្រ ដោយរដ្ឋាភិបាល ត្រូវបានចិញ្ចឹមបីបាច់ថែរក្សា ដោយមាតាបិតា អាណាព្យាបាល និងសហគមន៍ ។ ចំពោះកុមារកំព្រាដែលគ្មានទីពឹង ត្រូវបានចិញ្ចឹមបីបាច់ថែរក្សា ដោយមណ្ឌលរដ្ឋ ឬមណ្ឌលរបស់អង្គការ ។

បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីបញ្ហាសន្តិភាពនៅកម្ពុជាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានទទួលយកមកអនុវត្ត នូវអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ។ អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។ សិទ្ធិកុមារត្រូវបានរាជរដ្ឋាភិបាល យកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ។ គោលនយោបាយ ផែនការ និងកម្មវិធីជាតិត្រូវបានរៀបចំបន្ថែមទៀតជាបន្តបន្ទាប់ ដើម្បីការរស់រានមានជីវិត កិច្ចការពារ ការអភិវឌ្ឍ និងការរួមចំណែករបស់កុមារ ។

សិទ្ធិរបស់កុមារ ត្រូវបានទទួលស្គាល់ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដូចមានចែងក្នុងមាត្រា ៣១ និង៤៨ ។

## ផ្នែកទី ១ : ការលក់សរីរៈ

- **បរិបទច្បាប់ និងបទដ្ឋានអនុវត្ត**

***សំណួរទី១*** **:** ***តើប្រទេសអ្នកជាសមាជិកលិខិតូបករណ៍ពហុភាគី នៃការទប់ស្កាត់ និងការលុបបំបាត់ការលក់កុមារ (ឧទាហរណ៍ : អនុសញ្ញាបំពេញបន្ថែមឆ្នាំ១៩៥៦ ស្តីពីការលុបបំបាត់ទាសភាព អនុសញ្ញាឆ្នាំ១៩៩០ ស្តីពីសិទ្ធិកុមារ និងពិធីសារជ្រើសរើសផ្សេងៗនៃអនុសញ្ញានេះ ព្រមទាំងលិខិតូបករណ៍ គតិយុត្តផ្សេងៗទៀត របស់អង្គការអន្តរជាតិខាងការងារ) ដែរឬទេ ?***

***ចម្លើយ*** **:** កម្ពុជា ជាសមាជិកនៃលិខិតូបករណ៍ពហុភាគីនៃការទប់ស្កាត់ និងការលុបបំបាត់ការលក់កុមារ ។ កម្ពុជាបានផ្ដល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិមួយចំនួនមាន :

- អនុសញ្ញាបន្ថែមស្ដីពី *ការលុបបំបាត់ចោលទាសភាព ការជួញដូរទាសករ អង្គការចាត់តាំង និង ការអនុវត្ត ដែលមានលក្ខណ:ប្រហាក់ប្រហែលនឹងទាសភាព* ដែលបានផ្ដល់សច្ចាប័ននៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៥៧ ។

- កតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានផ្ដល់សច្ចាប័ននៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៩២ ។

- អនុសញ្ញាស្ដីពី *សិទ្ធិកុមារ* ដែលបានផ្ដល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។

- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៣៨ស្ដីពី *ការកម្រិតអាយុអប្បបរមាសម្រាប់ចូលធ្វើការងារ* ដែលរដ្ឋសភា បានផ្ដល់សច្ចាប័ននៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ ។

- ពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាស្ដីពីសិទ្ធិកុមារ អំពី*ការជួញដូរកុមារ ការធ្វើពេស្យាកម្ម កុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ* ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០២ ។

- លក្ខន្តិកៈទីក្រុងរ៉ូម ស្ដីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ចូលជាធរមាននៅឆ្នាំ២០០២ ។

- អនុសញ្ញាអន្តរជាតិខាងការងារលេខ១៨២ស្ដីពី *ការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ* ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ។

- ពិធីសារស្ដីពី *ការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និង កុមារ* ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

- អនុសញ្ញាក្រុងឡាអេ ស្ដីពី *កិច្ចការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស* ដែលរដ្ឋសភា បានផ្ដល់សច្ចាប័ននៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

***សំណួរទី២* : តើប្រទេសអ្នកបានធ្វើកិច្ចព្រមព្រៀងទ្វេភាគី ឬថ្នាក់តំបន់ជាមួយរដ្ឋដទៃទៀត ដើម្បីទប់ស្កាត់ និងលុបបំបាត់ការលក់កុមារ ក្នុងបរិបទនៃការផ្សាំសរីរៈកុមារ ដែរឬទេ ? បើមានសូមបង្ហាញ ?**

***ចម្លើយ*** **:** កម្ពុជាពុំបានធ្វើកិច្ចព្រមព្រៀងដោយឡែក ជាលក្ខណៈទ្វេភាគី ឬថ្នាក់តំបន់ លើបញ្ហាលុបបំបាត់ការលក់កុមារ ក្នុងបរិបទនៃការផ្សាំសរីរៈជាមួយប្រទេសណាមួយទេ ប៉ុន្តែការកាត់យកសរីរៈណាមួយ ត្រូវបានបញ្ចូលទៅក្នុងនិយមន័យនៃការកេងប្រវ័ញ្ចនៃអនុស្សរណៈយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ឆ្នាំ២០០៣ (ផ្នែកទី២ ប្រការ២ ចំណុច ក) ព្រមទាំងបានបញ្ចូលទៅក្នុងកិច្ចព្រមព្រៀង ជាមួយរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ដីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរស្ត្រី និងកុមារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ ឆ្នាំ២០០៥ (ផ្នែកទី១ មាត្រា១) ។

កម្ពុជាមានឆន្ទៈព្យាយាមរៀបចំឱ្យមាន កិច្ចព្រមព្រៀងទ្វេភាគី ជាមួយប្រទេសដទៃទៀត នាពេលខាងមុខ ដើម្បីរួមគ្នាបង្ក្រាប និងបង្ការអំពើជួញដូរមនុស្ស និងទប់ស្កាត់ព្រមទាំងលុបបំបាត់ការលក់កុមារ ក្នុងបរិបទនៃការផ្សាំសរីរៈ។

***<u>សំណួរទី៣</u> : សូមពណ៌នាពីច្បាប់ជាតិ (និងច្បាប់ថ្នាក់តំបន់ ខេត្ត រដ្ឋ បើសិនមាន) ដែលអាចអនុវត្តបាន ក្នុងការទប់ស្កាត់ ការប្រយុទ្ធប្រឆាំង និងការលុបបំបាត់ការលក់សរីរៈកុមារ ។***

***<u>ចម្លើយ</u>*** : សិទ្ធិមនុស្ស និងសិទ្ធិកុមារត្រូវបានការពារដោយច្បាប់ជាតិ ហើយគ្រប់វិធានការ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ឬលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីសំខាន់ៗផ្សេងៗទៀត នៃព្រះរាជាណាចក្រកម្ពុជា មានអានុភាពអាចទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងលុបបំបាត់ការលក់សរីរៈកុមារបាន។

នៅកម្ពុជាមិនទាន់មានច្បាប់ជាតិ ដែលចែងដោយឡែកអំពីការទប់ស្កាត់ ការប្រយុទ្ធប្រឆាំង និងការលុបបំបាត់ការលក់សរីរៈកុមារនៅឡើយទេ ប៉ុន្តែច្បាប់ជាតិមួយចំនួនរបស់កម្ពុជា អាចយកមកអនុវត្តបាន ដូចជា :

- រដ្ឋធម្មនុញ្ញ :

• *មាត្រា៣១ :* បានចែងទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ដូចមានចែងក្នុងធម្មនុញ្ញ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញានៃ អ.ស.ប។

• *មាត្រា៣៨-១ :* ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពាន លើរូបរាងកាយបុគ្គលណាមួយឡើយ។

• *មាត្រា៤៨-២ :* រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦។ ច្បាប់នេះមានគោលដៅ បង្ក្រាបអំពើពង្រត់មនុស្សយកទៅលក់ដូរ និងអំពើធ្វើអាជីវកម្មលើមនុស្ស ដើម្បីធ្វើនីតិសម្បទា និងលើកកម្ពស់ការគោរពប្រពៃណីជាតិល្អ ការការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការការពារសុខភាព និងសុខុមាលភាពរបស់ប្រជាជន។

- ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល (អ៊ុនតាក់) ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ :

• *មាត្រា ៣៥ :* ការបង្ខាំងមនុស្សដោយខុសច្បាប់

• *មាត្រា ៤១ :* អំពើបង្ករបួសស្នាមដោយចេតនា

- ច្បាប់ស្តីពីរបបសារព័ត៌មាន ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥។

• *មាត្រា១៤ :* សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយនូវអ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ ជាអាទិ៍

+ ពាក្យអសុរោះមិនគួរគប្បី ដូចជា អា មីង ជាដើម

+ ពាក្យដែលពណ៌នាចំៗអំពីសកម្មភាពរួមរក្ស

+ រូបគំនូរ ឬរូបថត ដែលបង្ហាញនូវ កេរ្តិ៍ភេទ ឬរូបអាក្រាត លើកលែងតែទិសដៅសម្រាប់អប់រំចេញ

+ រូបភាព ដែលប្រមាថមើលងាយ ប្រៀបធៀបទៅនឹងសត្វតិរច្ឆាន។

- ច្បាប់នៃស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០១។

• *មាត្រា ៣ :* ឃាតកម្មគិតទុកជាមុន

• *មាត្រា ៤ :* អំពើមនុស្សឃាតដោយចេតនា

- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលប្រកាសឱ្យប្រើ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥។ ត្រូវចាត់ទុកជាអំពើហិង្សា :

+ ការប៉ះពាល់ដល់ជីវិត

+ ការប៉ះពាល់ដល់បូរណភាពរូបរាងកាយ

+ ការធ្វើទារុណកម្ម ការធ្វើអំពើឃោរឃៅ

+ ការឈ្លានពានខាងផ្លូវភេទ។

- អនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ បានចែងថា :

*• មាត្រា ១៦ : " ការបួមយកឈាម ព្រមទាំងការកាត់យកសរីរៈជាលិកា កោសិកា ឬផ្នែកផ្សេងៗទៀតណាមួយ នៃរាងកាយរបស់មនុស្សមានជីវិត ឬមនុស្សស្លាប់នឹងអាចធ្វើទៅបាន តែក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ "។*

*• មាត្រា ៣៤ : " នៅគ្រប់ករណីទាំងអស់ ការពិនិត្យ ឬការថែទាំ ត្រូវតែបានទទួលការយល់ព្រមពីសាមីអ្នកជំងឺ។ កាលណាអ្នកជំងឺដែលមានស្មារតីធម្មតា បដិសេធការអនុវត្ត ការស្រាវជ្រាវ ឬវិធីព្យាបាលដែលបម្រុងធ្វើទៅលើខ្លួនគេ គ្រូពេទ្យត្រូវតែគោរពតាម ក្រោយពីបានពន្យល់អ្នកជំងឺឱ្យបានដឹងអំពីផលវិបាកនៃការបដិសេធនោះ។ បើអ្នកជំងឺមិនអាចសម្តែងឆន្ទៈរបស់ខ្លួនបាន គ្រូពេទ្យមិនអាចធ្វើអន្តរាគមន៍បានឡើយ បើពុំមានវត្តមានរបស់គ្រួសារអ្នកជំងឺនៅជាមួយ លើកលែងតែក្នុងករណីបន្ទាន់ ឬមិនអាចធ្វើការទាក់ទងនឹងគ្រួសារនោះបាន "។*

បច្ចុប្បន្ននេះ ក្រសួងយុត្តិធម៌កំពុងរៀបចំសេចក្តីព្រាងច្បាប់ថ្មី ស្តីពីការប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានលក្ខណៈលំអិតជាងច្បាប់មុន ហើយក្រសួងកិច្ចការនារីបានស្នើសុំឱ្យបញ្ចូលការលក់ដូរសរីរៈទៅក្នុងច្បាប់ថ្មីនេះផងដែរ។

ប្រទេសកម្ពុជា កំពុងខិតខំសម្របសម្រួល គ្រប់លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលកំពុងនៅជាធរមាន និងសេចក្តីព្រាងច្បាប់ថ្មីៗ ដើម្បីកែទាំងទម្រង់ និងខ្លឹមសារឱ្យមានន័យស្របតាមសេចក្តីបញ្ញត្តិ ជាអន្តរជាតិ និងអាស៊ាន។

***<u>សំណួរទី៤</u> : សូមបង្ហាញពីស្ថាប័នសាធារណៈផ្សេងៗ ដែលទទួលខុសត្រូវក្នុងការទប់ស្កាត់ការប្រយុទ្ធប្រឆាំងនឹងការលុបបំបាត់ការលក់សរីរៈកុមារ រាប់បញ្ចូលទាំងតួនាទី និងសកម្មភាពរបស់ស្ថាប័ននោះផង ។***

***<u>ចម្លើយ</u> :*** នៅប្រទេសកម្ពុជាបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។ ស្ថាប័នសាធារណៈផ្សេងៗ មានភារកិច្ចផ្សេងៗគ្នា ដូចតទៅ :

## ១. ស្ថាប័ននីតិបញ្ញត្តិ

រដ្ឋសភា និងព្រឹទ្ធសភា មានគណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹង។ គណៈកម្មការនេះមានភារកិច្ចទទួល និងដោះស្រាយគ្រប់ពាក្យបណ្ដឹង ឬត្រូវបញ្ជូនពាក្យបណ្ដឹងទៅស្ថាប័នមានសមត្ថកិច្ច តាមសំណូមពររបស់ប្រជាពលរដ្ឋ ដែលទទួលរងនូវអំពើរំលោភលើសិទ្ធិ និងសេរីភាពរបស់ខ្លួន ឬសិទ្ធិកុមារ ។

## ២. ស្ថាប័ននីតិប្រតិបត្តិ

រាជរដ្ឋាភិបាលបានបង្កើតក្រសួង ស្ថាប័នជំនាញមួយចំនួនដែលមានតួនាទី ភារកិច្ចពាក់ព័ន្ធទៅនឹងការងារសុខភាព ការអភិវឌ្ឍ និងការលើកកម្ពស់ការយល់ដឹង និងកិច្ចការពារសិទ្ធិកុមារ ។ បណ្ដាក្រសួង ស្ថាប័នទាំងនោះមាន :

ក- ក្រសួងមហាផ្ទៃ មាននាយកដ្ឋានពីរ : នាយកដ្ឋានព្រហ្មទណ្ឌ ដែលមានភារកិច្ចស្រាវជ្រាវ ស៊ើបអង្កេត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ និងនាយកដ្ឋានប្រឆាំងការជួញដូរ និងការពារអនីតិជន មានភារកិច្ចផ្ដល់សេវាឯកទេសក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបរាល់សកម្មភាពជួញដូរ អាជីវកម្មផ្លូវភេទលើនីតិជន និងអនីតិជន។ នាយកដ្ឋាននេះមានផែនការ (០២៣ ផ.ក) ដែលមានគោលការណ៍ដូចជា ការក្ដាប់សភាពការណ៍បទល្មើសជួញដូរមនុស្ស វិធានការបង្ការទប់ស្កាត់ វិធានការបង្ក្រាបគ្រប់រូបភាព ប្រឆាំងការជួញដូរមនុស្ស អំពើអាសអាភាស ឬអំពើអនាចារលើកុមារ ធ្វើសហប្រតិបត្តិការជាមួយក្រសួងមន្ទីរពាក់ព័ន្ធ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្លាស់ប្ដូរព័ត៌មានដែលទាក់ទងនឹងអំពើជួញដូរមនុស្ស បង្កើតក្រុមប្រចាំការអន្តរាគមន៍បន្ទាន់ និងមានទូរស័ព្ទពិសេសមួយខ្សែសម្រាប់ទទួលបណ្ដឹង ឬសេចក្ដីរាយការណ៍បន្ទាន់ដើម្បីធ្វើអន្តរាគមន៍ ។

ខ- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាននាយកដ្ឋានសុខុមាលភាពកុមារ មានភារកិច្ចកសាង និងពង្រីងបណ្ដាញផ្ដល់សេវាដល់កុមារ ដែលត្រូវការកិច្ចការពារពិសេសនៅតាមសហគមន៍។ ផ្ដល់សេវាការពារទប់ស្កាត់ប្រឆាំង ការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ ។ការិយាល័យសុំកូននៃនាយកដ្ឋាននេះ ធ្វើការងារសុំកូនអន្តរប្រទេសក្នុងគោលបំណងរកឪពុកម្ដាយឱ្យកុមារកំព្រាគ្មានទីពឹង និងការពារកុមារទាំងនោះពីការត្រូវគេយកទៅជួញដូរ ឬវះកាត់សរីរៈ ។ ទន្ទឹមនេះដែរ នាយកដ្ឋានមានកម្មវិធីបណ្ដាញការពារកុមារ ក្នុងសហគមន៍នៅខេត្តក្រុងចំនួន៦ ដែលមានការឧបត្ថម្ភគាំទ្រពីអង្គការយូនីសេហ្វ។

គ- ក្រសួងសុខាភិបាល គ្រប់គ្រងមន្ទីរពេទ្យទាំងអស់ ទាំងរបស់រដ្ឋ និងឯកជន។ មន្ទីរពេទ្យធ្វើការព្យាបាល និងវះកាត់ស្របទៅតាមបច្ចេកទេសវេជ្ជសាស្ត្រ និងគោលការណ៍ណែនាំរបស់ក្រសួង ព្រមទាំងគោរពតាមអនុក្រឹត្យស្ដីពីក្រមសីលធម៌គ្រូពេទ្យ ដែលបានចែងអំពីការបូមយកឈាម ព្រមទាំងការកាត់យកសរីរៈ ជាលិកា កោសិកា ឬផ្នែកផ្សេងៗទៀតណាមួយនៃរាងកាយរបស់មនុស្សមានជីវិត ឬមនុស្សស្លាប់ និងអាចធ្វើទៅបានតែក្នុងលក្ខខណ្ឌកំណត់ដោយច្បាប់ និងគ្រប់ករណីទាំងអស់ ការពិនិត្យ ឬការថែទាំ ត្រូវតែបានទទួលការយល់ព្រមពីសាមីអ្នកជំងឺ។

ឃ- ក្រសួងកិច្ចការនារី មានកម្មវិធីអប់រំប្រជាជនពីបញ្ហាជួញដូរមនុស្ស និងដឹកនាំការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

ង- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មាននាយកដ្ឋានការងារកុមារ ដែលមានតួនាទី និងទទួលខុសត្រូវលើការងារកុមារ និងមានភារកិច្ចធ្វើការងារ ដែលពាក់ព័ន្ធទៅនឹងការជួញដូរកុមារ ការកេងប្រវ័ញ្ចពលកម្មកុមារ ការជួយសង្គ្រោះដល់កុមារងាយរងគ្រោះ ប្រឆាំងនឹងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងកុមារ ។

ច- ក្រសួងយុត្តិធម៌ បានបញ្ចូលគោលការណ៍នៃសិទ្ធិកុមារ ទៅក្នុងសេចក្តីព្រាងច្បាប់មួយចំនួន និងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ឆ- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ( ក.ជ.ក.ក.) ជាស្ថាប័នអន្តរក្រសួង ដែលមានសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ជាប្រធានកិត្តិយស ។

ក.ជ.ក.ក មានតួនាទីសម្របសម្រួល ត្រួតពិនិត្យតាមដាន និងវាយតម្លៃលើគោលនយោបាយ និងកម្មវិធីទាំងឡាយដែលទាក់ទងទៅនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ និងការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារកម្ពុជា និងមានភារកិច្ចទាក់ទាញមតិគាំទ្រ រៀបចំសេចក្តីព្រាងគោលនយោបាយ ច្បាប់ ផែនការដែលពាក់ព័ន្ធនឹងកុមារ រៀបចំរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

កន្លងមក ក.ជ.ក.ក បានជំរុញការលើកកម្ពស់សិទ្ធិកុមារ តាមរយៈការធ្វើសិក្ខាសាលា ជូនដល់មន្ត្រីរាជការ ការរៀបចំកម្មវិធីអប់រំ តាមប្រព័ន្ធផ្សព្វផ្សាយ ការរៀបចំមិទ្ទិញអបអរសាទរទិវាកុមារអន្តរជាតិ ១ មិថុនា ដែលមានប្រមុខរាជរដ្ឋាភិបាល សមាជិករដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំក្រសួង អង្គការនានា និងកុមារចូលរួម ។ ទន្ទឹមនេះដែរ រួមចំណែកក្នុងការដោះស្រាយបញ្ហាជួញដូរកុមារ ក.ជ.ក.ក បានសម្របសម្រួល និងដឹកនាំការធ្វើផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ២០០០-២០០៤ និងបានរៀបចំសេចក្តីព្រាងផែនការជាតិលើកទី២ ដែលត្រូវបានអនុវត្តដោយក្រសួងពាក់ព័ន្ធ ។

ញ- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាមានភារកិច្ចអនុវត្ត កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ការប្រឆាំងទារុណកម្ម ឃោរឃៅព្រៃផ្សៃ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ ការលុបបំបាត់គ្រប់ទម្រង់នៃការរើសអើងប្រកាន់ពូជសាសន៍ ។

### ៣- <u>ស្ថាប័នតុលាការ</u> :

ជនណាដែលបានប្រព្រឹត្តបទល្មើសគ្រប់រូបភាព កាលណាមានអង្គហេតុ និងភស្តុតាងគ្រប់គ្រាន់ ដើម្បីបញ្ជាក់ពីអំពើល្មើសរបស់ជននោះ គឺត្រូវតែទទួលការកាត់ទោសតាមច្បាប់ ដោយអនុលោមតាមសណ្ឋាន និងផលនៃបទល្មើស ពីខ្នាតតូចតាចទៅកាន់មធ្យម និងចូលជាបទ្ទុកធ្ងន់ធ្ងរ ដូចជាត្រូវឆ្លងកាត់ :

១- តុលាការជាន់ទាប : តុលាការខេត្ត-ក្រុង ដែលតាំងនៅគ្រប់ខេត្ត-ក្រុង ។

២- តុលាការជាន់ខ្ពស់ : មានសាលាឧទ្ធរណ៍១ និងតុលាការកំពូល១ តាំងនៅទីក្រុងភ្នំពេញ ។ ករណីមានបទ

ល្មើសទាក់ទងនឹងកុមារ ឬ នីតិជន ជាសមត្ថកិច្ចរបស់តុលាការ ដែលជំនុំជម្រះគ្រប់រឿងក្តីទាំងអស់។

ក្រៅពីស្ថាប័នជាតិគ្រប់ជាន់ថ្នាក់ ក៏នៅមានអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលច្រើនទៀត ដែលមានទីតាំងនៅទីក្រុងភ្នំពេញ និងតាមបណ្តាលខេត្ត/ក្រុង។ អង្គការទាំងនេះមានភារកិច្ចតាមដាន ស៊ើបអង្កេត ឃ្លាំមើលជាប្រចាំ និង រាយការណ៍ជាបន្ទាន់ កាលណាបានជួបប្រទះជាក់ស្តែង ឬបានទទួលរបាយការណ៍ ស្តីពីសកម្មភាពរំលោភលើសិទ្ធិកុមារ ព្រមទាំងផ្តល់សេវាសង្គ្រោះ និងសេវាផ្នែកច្បាប់ចាំបាច់មួយចំនួន ជួយដល់ជនរងគ្រោះផងដែរ។

- **<u>បរិបទអង្គហេតុ</u>**

***<u>សំណួរទី៥</u> : តើធ្លាប់មានសេចក្តីរាយការណ៍ពីឧប្បត្តិហេតុ ទាក់ទងនឹងការលក់ ឬការជួញដូរសេរីរៈដែរឬទេ? បើមានសូមបញ្ជាក់ផង ។***

***<u>សំណួរទី៦</u> : តើធ្លាប់មានសេចក្តីរាយការណ៍ពីឧប្បត្តិហេតុ ទាក់ទងនឹងការលក់ ឬការជួញដូរសេរីរៈ<u>របស់កុមារ</u> ដែរឬទេ ? បើមានសូមបញ្ជាក់ផង ។***

***<u>ចម្លើយទី ៥ និងទី ៦</u>*** **:** មិនធ្លាប់មានសេចក្តីរាយការណ៍ពីឧប្បត្តិហេតុទាក់ទងនឹងការលក់ ឬការជួញដូរសេរីរៈកុមារ និងមនុស្សពេញវ័យទេ។

***<u>សំណួរទី៧</u> : បើសិនធ្លាប់មានករណីលក់ ឬការជួញដូរសេរីរៈរបស់កុមារ តើមានវិធានការអ្វីខ្លះយកមកអនុវត្ត ? តើមានបណ្តឹងដែរឬទេ ? បើសិនជាមាន តើបណ្តឹងទាំងនោះចាប់ផ្តើមយ៉ាងដូចម្តេច ?***

***<u>ចម្លើយ</u> :***

*ក-វិធានការជាសកល និងជាក់ស្តែង*

- កម្ពុជាពុំធ្លាប់កើតមានករណីលក់ ឬ ជួញដូរសេរីរៈរបស់កុមារទេ។ បើសិនមានករណីនេះកើតឡើង ស្ថាប័ន មានសមត្ថកិច្ចនឹងអនុវត្តវិធានច្បាប់ ដើម្បីបង្ក្រាប និងផ្តន្ទាទោសជនល្មើសតាមច្បាប់។

*ខ-អំពីបណ្តឹង*

- បើមានបណ្តឹងដែលជាប់ទាក់ទងនៅក្នុងការងារនេះ អាជ្ញាធរមានសមត្ថកិច្ចមានកាតព្វកិច្ចតាមដាន ស៊ើបអង្កេត ប្រមូលភស្តុតាង ទទួលយកគ្រប់ព័ត៌មាន របាយការណ៍ និងដោះស្រាយគ្រប់បណ្តឹងទូទៅ តាមរយៈប្រពន្ធ័តុលាការ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ មាត្រា៩ ចែងថា *" បុគ្គលដែលយល់ឃើញថា ខ្លួនត្រូវបានរងគ្រោះដោយអំពើល្មើសអាចដាក់ពាក្យប្តឹងជាមួយការចោទប្រកាន់របស់រដ្ឋអាជ្ញា ដើម្បីទាមទារសំណងជំងឺចិត្ត ។"*

***<u>សំណួរទី៨</u> : តើធ្លាប់មានស្ថានភាពដែលកុមារត្រូវចាប់ខ្លួន ឬបាត់ខ្លួន ត្រូវបានរកឃើញ(រស់ ឬស្លាប់) ដោយមានការបាត់បង់សរីរៈដែរឬទេ ? បើមានតើសរីរៈអ្វីដែលត្រូវបានគេដកចេញ ? តើវិធានការអ្វីខ្លះដែលយកមកអនុវត្តក្នុងករណីនេះ ?***

***<u>ចម្លើយ</u>*** : កម្ពុជាពុំធ្លាប់មានសេចក្ដីរាយការណ៍ ឬបណ្ដឹងណាមួយស្ដីពីឧប្បត្តិហេតុដែលកុមារត្រូវចាប់ខ្លួន ឬបាត់ខ្លួនត្រូវ បានរកឃើញដោយមានការបាត់បង់សរីរៈនោះទេ ។

***<u>សំណួរទី៩</u> : តើធ្លាប់បានរាយការណ៍ពីឧប្បត្តិហេតុទាក់ទងនឹងពិធីសាសនាផ្នែកនិកាយ ឬធ្មប់ដែលអាចធ្វើឱ្យមានការដកសរីរៈដែរឬទេ ? បើមានចូររៀបរាប់ ។***

***<u>ចម្លើយ</u>*** : នៅក្នុងប្រទេសកម្ពុជា ពុំមានសេចក្ដីរាយការណ៍ជាផ្លូវការ ពីឧប្បត្តិហេតុទាក់ទងនឹងពិធីសាសនាផ្នែកនិកាយ ឬធ្មប់ដែលអាចធ្វើឱ្យមានការដកសរីរៈនោះទេ។

## <u>ផ្នែកទី២</u> : កម្មវិធីដោះស្រាយជាបន្ទាន់ ក្នុងករណីមានការចាប់ខ្លួន ឬការបាត់ខ្លួនកុមារ

- **<u>បរិបទច្បាប់ និងបទដ្ឋានអនុវត្ត</u>**

***<u>សំណួរទី១០</u> : តើប្រទេសអ្នកមានវិធានការច្បាប់ ឬរដ្ឋបាល ដើម្បីទប់ស្កាត់ការចាប់ខ្លួន ឬការបាត់ខ្លួនកុមារដែរឬទេ ? បើមានចូរពណ៌នាវិធានការ ដែលអនុវត្តថ្នាក់ជាតិ ( តំបន់ ខេត្ត រដ្ឋ )***

***<u>ចម្លើយ</u>*** : ប្រទេសកម្ពុជាមានវិធានការច្បាប់ ឬរដ្ឋបាលមួយចំនួន ដើម្បីទប់ស្កាត់ការចាប់ខ្លួន ឬការបាត់ខ្លួនរបស់កុមារ ។ វិធានការទាំងនោះរួមមាន :

*ក- វិធានការច្បាប់ :* ដូចចម្លើយទី៣

*ខ- វិធានការរដ្ឋបាល :* បើមានការបាត់ខ្លួនកុមារ ឬ មនុស្សពេញវ័យ ហួសពីរយៈពេល ២៤ម៉ោង ឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលនៅជិតទីនោះដើម្បីឱ្យជួយស្វែងរក។

រាជរដ្ឋាភិបាលកម្ពុជា បានចេញសេចក្ដីប្រកាសលេខ០១/សប្រក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០០ ស្ដីពីវិធានការចាត់តាំងអនុវត្តផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលបានអំពាវនាវដល់ :

- មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ចូរជៀសវាងដាច់ខាត កុំចូលពាក់ព័ន្ធ ឬ ធ្វើខ្នងបង្អែកឱ្យជនទុច្ចរិតប្រកបរបរជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ជនណាដែលប្រព្រឹត្តល្មើសនឹងត្រូវផ្ដន្ទាទោសតាមច្បាប់។ មាតាបិតា អាណាព្យាបាល ត្រូវយកចិត្តទុកដាក់ពិនិត្យ តាមដានឱ្យបានជិតដល់ នូវរាល់សកម្មភាពរបស់កូនខ្លួន ហើយធ្វើការអប់រំណែនាំជាប្រចាំ ដើម្បីកុំឱ្យកុមារធ្លាក់ក្នុងអំពើអបាយមុខផ្សេងៗ ដែលងាយដល់ជនទុច្ចរិតអូសទាញបម្រើគោលដៅឧក្រិដ្ឋកម្ម។

***សំណួរទី១១*** : ***តើប្រទេសអ្នកមានវិធានការច្បាប់ ឬរដ្ឋបាលដែលអនុញ្ញាតឱ្យប្រកាសអាសន្នដល់ប្រជាជនក្នុងករណីមានការចាប់ខ្លួន ឬការបាត់ខ្លួនកុមារដែរឬទេ ? បើមានសូមពណ៌នាអំពីវិធានការផ្សេងៗដែលបានអនុវត្ត និងសាធារណៈជនដែលជាក្រុមមុខសញ្ញា ( តំបន់ ភូមិសាស្ត្រ និងប្រភេទសាធារណៈជន )***

***ចម្លើយ*** :

- នៅកម្ពុជាពុំធ្លាប់មានការប្រកាសអាសន្នដល់ប្រជាជនក្នុងករណីមានការចាប់ខ្លួន ឬការបាត់ខ្លួនកុមារទេ។

- នៅក្នុងករណីមានការចាប់ខ្លួន ឬការបាត់ខ្លួនកុមារ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអាជ្ញាធរមានសមត្ថកិច្ច អាចផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន ជាពិសេសត្រូវរាយការណ៍ទៅស្ថាប័នមានសមត្ថកិច្ច។

- **បរិបទអង្គហេតុ**

***សំណួរទី១២*** : ***ចាប់តាំងពីមានការអនុវត្តនូវវិធានការប្រកាសអាសន្ន តើអត្រាជោគជ័យក្នុងការរកកុមារត្រូវបានចាប់ខ្លួន ឬបាត់ខ្លួនបានកើនឡើងដែរឬទេ ? បើសិនជាមាន តើអ្វីជាមូលហេតុសំខាន់នៃភាពជោគជ័យនេះ ? បើគ្មាន តើវិធានការបន្ថែមអ្វីខ្លះដែលត្រូវបានអនុវត្ត ?***

***ចម្លើយ*** : នៅកម្ពុជាមិនដែលកើតមានការលក់សិរីរៈកុមារឡើយ។

***សំណួរទី១៣*** : ***តើធ្លាប់មានស្ថានភាពដែលកុមារត្រូវបានរកឃើញវិញមានជីវិត ហើយជនល្មើសត្រូវបានចាប់ខ្លួនបន្ទាប់ពីការអនុវត្តវិធានការប្រកាសអាសន្ននោះ ដែរឬទេ? បើមានចូរពណ៌នាពីប្រវត្តិនៃព្រឹត្តិការណ៍ទាំងនោះ ហើយថាតើកម្មវិធីដោះស្រាយជាបន្ទាន់បានរួមចំណែក ក្នុងការបញ្ចប់ការចាប់ខ្លួន ឬ ការបាត់ខ្លួនយ៉ាងដូចម្តេច ?***

***ចម្លើយ*** : នៅកម្ពុជាពុំធ្លាប់មានករណីកុមារត្រូវបាត់ខ្លួន ឬចាប់ខ្លួនដើម្បីវះកាត់សិរីរៈទេ។

**សេចក្តីសន្និដ្ឋាន** :

រាជរដ្ឋាភិបាលកម្ពុជា មានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះសំណួរទាំងឡាយខាងលើ ទោះបីហេតុការណ៍ខ្លះពុំទាន់កើតមាននៅក្នុងកម្ពុជានៅឡើយក្តី។ ឆ្លងតាមការយកចិត្តទុកដាក់របស់អង្គការសហប្រជាជាតិ កម្ពុជាសង្ឃឹមថា អង្គការសហប្រជាជាតិនឹងចែករំលែកបទពិសោធ ព្រមទាំងផ្តល់មធ្យោបាយដើម្បីឱ្យកម្ពុជារឹតតែមានលទ្ធភាព ធ្វើកិច្ចបង្ការ ទប់ស្កាត់ អំពើអវិជ្ជមានទាំងនេះឱ្យបានកាន់តែប្រសើរឡើង។

~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~